**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ៣៥១ **គ.ជ.ប**

# គោលការណ៍
# សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយ ឱ្យគណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួន ក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចេញគោលការណ៍សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយឱ្យគណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ ដល់ស្ថានីយវិទ្យុ និងទូរទស្សន៍ដែលមានបំណងរៀបចំការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ដោយលក់ ឬជួលម៉ោងផ្សាយទៅឱ្យគណបក្សនយោបាយ ដោយត្រូវអនុវត្តដូចខាងក្រោម៖

## ១. សេចក្តីប្រកាសជាសាធារណៈ

១.១ ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវប្រកាសជាសាធារណៈអំពីចំនួនម៉ោងដែលខ្លួនមានសម្រាប់លក់ ឬ ជួលក្នុងរយៈពេល ១ (មួយ) ថ្ងៃ និងចំនួនម៉ោងដែលមានសម្រាប់លក់ ឬ ជួលក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ នៃដំណាក់កាលឃោសនាបោះឆ្នោត។

១.២ ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវប្រកាសផ្សព្វផ្សាយជាសាធារណៈ អំពីតម្លៃដែលលក់ ឬជួលនោះ។

១.៣ ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវជូនដំណឹងអំពីការលក់ ឬជួលម៉ោងផ្សាយនេះ ទៅគ្រប់គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា-រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ហើយសេចក្តីជូនដំណឹងនេះត្រូវចម្លងជូនមក គ.ជ.ប ចំនួន ១ (មួយ) ច្បាប់។

១.៤ ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវផ្តល់ព័ត៌មានមក គ.ជ.ប អំពីឈ្មោះគណបក្សនយោបាយដែលបានទិញ ឬជួលម៉ោងផ្សាយ។

## ២. វិធីលក់ ឬជួលម៉ោងឱ្យគណបក្សនយោបាយ

២.១ ការលក់ ឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយរបស់គណបក្សនយោបាយ ត្រូវផ្អែកទៅតាមគោលការណ៍ស្មើភាព តម្លៃស្មើៗគ្នា និងតាមលំដាប់មុនក្រោយ។

២.២ ម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវយកចំនួនម៉ោងសរុបដែលលក់ ឬជួលចែកជាមួយនឹងចំនួនគណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ រួចលក់តែចំណែកម៉ោងដែលគណបក្សនយោបាយនីមួយៗត្រូវទទួលបាន ទៅឱ្យគណបក្សនយោបាយនីមួយៗ។

២.៣ ក្នុងករណីមានគណបក្សនយោបាយតិច ឬគណបក្សនយោបាយតែមួយទិញ ឬជួលម៉ោងផ្សាយ ម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍ អាចលក់ ឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយដែលមានលទ្ធភាពទិញ ឬជួលនោះ នូវរយៈពេលយ៉ាងច្រើន ៣ (បី) ដងនៃរយៈពេលផ្សព្វផ្សាយតាមគោលការណ៍ស្មើភាព ដូចមានចែងក្នុងចំណុច ២.២ ខាងលើ។

២.៤ ការលក់ ឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយ មិនអនុញ្ញាតឱ្យម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍ លក់ ឬជួលម៉ោងផ្តាច់មុខឱ្យគណបក្សនយោបាយណាមួយឡើយ។

## ៣. សិទ្ធិ និងការទទួលខុសត្រូវ

៣.១ ម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍ ពុំត្រូវទទួលខុសត្រូវចំពោះខ្លឹមសារនៃការផ្សព្វផ្សាយគោលនយោបាយ របស់គណបក្សនយោបាយឡើយ។

៣.២ គណបក្សនយោបាយត្រូវទទួលខុសត្រូវចំពោះខ្លឹមសារនៃការឃោសនារបស់ខ្លួន។

៣.៣ ម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវគោរពតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងគោលការណ៍នេះ ដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងអំឡុងពេលឃោសនាបោះឆ្នោត និងត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត។

៣.៤ ក្នុងករណី គ.ជ.ប រកឃើញថា ខ្លឹមសារនៃការឃោសនារំលោភលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គ.ជ.ប មានសិទ្ធិស្នើឱ្យគណបក្សនយោបាយធ្វើការកែតម្រូវ ហើយប្រសិនបើនៅតែមិនព្រមកែតម្រូវ គ.ជ.ប មានសិទ្ធិដកហូត ឬបញ្ឈប់លែងឱ្យស្ថានីយវិទ្យុ និងទូរទស្សន៍នោះធ្វើការផ្សព្វផ្សាយនូវខ្លឹមសារឃោសនាបោះឆ្នោតទាំងស្រុង និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មីនា ឆ្នាំ២០២៤

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ